មេរៀនទី ៣ គោលការណ៍របស់គ្រិស្តបរិស័ទ ក្នុងការដោះស្រាយបញ្ហា

ប្រសិនបើអ្នកនៅក្នុងទីឃុំឃាំង មានអ្នកយាមប្រដាប់ដោយអាវុធ នៅយាមជុំជិត និង បានដកហូតសិទ្ធិសេរីភាពរបស់អ្នកមិនឲ្យទៅណាមកណាបានតាមចិត្ត អ្នកប្រហែលជានឹងនិយាយថា អ្នកមានបញ្ហាមួយ ឬ បញ្ហាច្រើនជាក់ជាមិនខាន! អ្នកអាចនឹងមានអារម្មណ៍ថា ដំណោះស្រាយល្អបំផុតសម្រាប់បញ្ហានេះ អាចជាសេរីភាព!

នៅពេលដែលលោកសាវ័កប៉ូល បានដឹងថាខ្លួនគាត់ស្ថិតនៅក្នុងបញ្ហាបែបនេះ គាត់មិនបានឃើញថាវាជាបញ្ហាសោះឡើយ។ ផ្ទុយទៅវិញ លោកបានឃើញវាជាការចាត់តាំងដ៏វិសុទ្ធរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់លោក។ លោកបានចាត់ទុកវាជា *អភ័យឯកសិទ្ធិ* ដែលព្រះជាម្ចាស់ បានប្រទានមកឲ្យគាត់ដើម្បីការពារ និង បង្កើតបានជាដំណឹងល្អ (គម្ពីរភីលីព ១:៧) ។ លោកបានចាត់ទុកវាជា *ឱកាស* ដែលលោកបានទទួលមក ដើម្បីចែកចាយអំពីព្រះយេស៊ូគ្រិស្ត ជាមួយនឹងឆ្មាំយាមវាំង និង ជាមួយមិត្តរួមបេសកកម្មរបស់លោក នៅក្នុងទីក្រុង។នៅក្នុងមេរៀនទី១ យើងបាននិយាយអំពីការឆ្លើយតបរបស់លោកប៉ូលទៅនឹងការជាប់ឃុំឃាំងរបស់លោក។ លោកបានរីករាយ ព្រោះលោកបានដឹងថាព្រះជាម្ចាស់កំពុងតែប្រើប្រាស់លោក ទោះបីជាកំពុងនៅក្នុងគុកក៏ដោយ។

ទស្សនៈវិស័យដែលល្អបំផុត ក្នុងការប្រឈមមុខជាមួយនឹងបញ្ហា ប្រហែលជាត្រូវមើលពួកវា ថា ជាឱកាសដើម្បីអនុវត្តជំនឿ ដើម្បីអនុវត្តការទុកចិត្តព្រះអម្ចាស់ ដើម្បីបញ្ហាពីភាពស្មោះត្រង់ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ និង ដើម្បីបានការទទួលស្គាល់ទ្រង់វិញផងដែរ។ ជំនឿជាគ្រិស្តបរិស័ទរបស់អ្នកនឹងបានកាន់តែរឹងមាំឡើងនៅពេលណាដែលអ្នកធ្វើការរួមជាមួយព្រះអម្ចាស់ដើម្បីស្វែងរកដំណោះស្រាយសម្រាប់បញ្ហាជីវិត។ ទ្រង់ពិតជាដំណោះស្រាយដ៏ត្រឹមត្រូវសម្រាប់បញ្ហាគ្រប់បែបយ៉ាង!

នៅក្នុងមេរៀននេះ យើងនឹងពិចារណាអំពីគោលការណ៍ខ្លះៗរបស់គ្រិស្តបរិស័ទ សម្រាប់ការដោះស្រាយបញ្ហា។នៅពេលដែលអ្នកធ្វើតាមគោលការណ៍ទាំងនេះ អ្នកអាចរំពឹងទុកថា ព្រះជាម្ចាស់នឹងធ្វើការរួមជាមួយអ្នក ហើយអ្នកអាចរំពឹងទុកថា នឹងបានឆ្លងកាត់បញ្ហាគ្រប់បែបយ៉ាង ជាមួយនឹងអំណរ និង ជ័យជម្នះ!

គម្រោងមេរៀន

ក. ចាប់ផ្ដើមជាមួយនឹងរបៀបរបស់គ្រិស្ដបរិស័ទ
ខ. ជៀសវាងការឆ្លើយតបដែលខុសឆ្គង
គ. ប្រើប្រាស់វិធីសាស្ត្រប្រព័ន្ធ
ឃ. អរសប្បាយ និង អរព្រះគុណ

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. វាយតម្លៃស្ថានភាពរបស់អ្នក ដែលទាក់ទងនឹងការបែកចេញ និង ការស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។
២. ស្គាល់ពីការឆ្លើយតបខុសឆ្គងតាមរយៈឧទាហរណ៍ដែលបានផ្ដល់ឲ្យ និង ធ្វើលំហាត់ផ្ទាល់ខ្លួន។
៣. បកស្រាយថា ហេតុអ្វីបានជាវាមានសារៈសំខាន់ម្ល៉េះ ដែលមិនត្រូវព្យាយាមដោះស្រាយបញ្ហារបស់អ្នក ដោយសមត្ថភាពមនុស្សតែម្យ៉ាងនោះ។
៤. ធ្វើតារាងតាមដានមួយ ដើម្បីតាមដានការដោះស្រាយស្ថានភាពរបស់បញ្ហា ដោយផ្អែកលើវិធីសាស្ត្រដែលបានផ្ដល់ឲ្យ និង ដាក់តារាងតាមដាននោះទៅលើបញ្ហាដែលបានផ្ដល់ឲ្យ។
៥. ប្រាប់ពីគោលការណ៍មួយដែលបកស្រាយពីអ្វីដែលបានជួយលោកសាវ័កប៉ូលឲ្យចេះស្កប់ចិត្តនៅក្នុងគ្រប់កាលៈទេសៈទាំងអស់។

សកម្មភាពក្នុងការសិក្សា

១. សិក្សាមេរៀននេះដោយយោងទៅតាម ការណែនាំដែលបានផ្ដល់ឲ្យនៅក្នុងសកម្មភាពក្នុងការសិក្សា នៃមេរៀនទី១ ។ ត្រូវប្រាកដថា អ្នកបានអានខគម្ពីរទាំងអស់ដែលបានដាក់ឲ្យ និង ឆ្លើយរាល់សំណួរសិក្សាទាំងអស់ មុនពេលទៅបើកមើលចម្លើយដែលយើងផ្ដល់ជូន នៅចុងបញ្ចប់នៃមេរៀន។
២. បើកទៅមើលពាក្យសំខាន់ ។ ប្រសិនបើពាក្យណាដែលអ្នកមិនធ្លាប់ជួបពីមុនមក ចូរមើលនិយមន័យរបស់វានៅក្នុងអក្ខរានុក្រម។
៣. ធ្វើការប្រឡងផ្ទាល់ខ្លួន នៅចុងបញ្ចប់នៃមេរៀន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។ ចូររំឭកចំណុចណាដែលអ្នកឆ្លើយមិនបានត្រឹមត្រូវ។
៤. បន្ទាប់ពីបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូររំឭកមេរៀនទី១ដល់ទី៣ (នៃជំពូកទីមួយ) ឡើងវិញ។ បន្ទាប់មកបំពេញ *ការប្រឡងជំពូកទីមួយ* ។

ពាក្យសំខាន់

ការចោទប្រកាន់	ប្រឈមមុខ	បំពាន
ការសម្របសម្រួល	ផលលំបាក	ប្រតិកម្មតប
កំណាច	ច្រាស់	ការចុះចាញ់
ជម្រើស	ដកចេញ	សងសឹក
ភាពល្ងីងល្ងរចត់	ភាពជ្រុលនិយម	អធិធម្មជាតិ
ចំណែកថ្នាក់	សន្ទុះចិត្ត	មិនចេះខឹង
ចិត្តអាសូរ	សង្រួមចិត្ត	ការដកចេញ
ចរិយាមារយាទ		

ក. ចាប់ផ្ដើមជាមួយនឹងរបៀបរបស់គ្រិស្ដបរិស័ទ

វត្ថុបំណងទី១. *វាយតម្លៃស្ថានភាពរបស់អ្នក ដែលទាក់ទងនឹងការបែកចេញ និង ការស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។*

សំណួរសំខាន់ៗចំនួនពីរយ៉ាង

ថ្មីៗនេះខ្ញុំ បានឮអំពីគូស្វាមីភរិយាថ្មីមួយគូ ដែលបានសម្រេចចិត្តធ្វើការលែងលះគ្នា។ នៅពេលដែលគេបានរៀបអាពាហ៍ពិពាហ៍ ពួកគេគឺជាគ្រិស្ដបរិស័ទដ៏រឹងមាំទាំងពីរនាក់ ដែលបានចូលរួមនៅក្នុងការថ្វាយបង្គំក្នុងព្រះវិហារ ប្រកបដោយជំនឿ ហើយអានព្រះគម្ពីរ និង អធិស្ឋានរួមគ្នាផងដែរ។ ប៉ុន្ដែនៅពេលដែលគាត់កាន់តែជាប់រវល់ជាមួយនឹងការងាររបស់គាត់ ហើយប្រពន្ធរបស់គាត់កាន់តែរវល់ជាមួយកូនទាំងពីរនាក់ដែលបានកើតមកនៅក្នុងអំឡុងពេលបួនឆ្នាំដំបូងបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ហើយនោះ ជីវិតរបស់ពួកគេកាន់តែរវល់យ៉ាងខ្លាំង។ ទម្លាប់ប្រចាំថ្ងៃក្នុងការអានព្រះគម្ពីរ និង អធិស្ឋានរួមគ្នាកាន់តែថយចុះ ហើយពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេកាន់តែមានហេតុផលច្រើន ដែលមិនឲ្យពួកគេទៅព្រះវិហារ។

ដូច្នេះហើយបានជា នៅពេលដែលបញ្ហាចាប់ផ្ដើម ខិតចូលមកក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ ពួកគេមិនរៀបចំវិញ្ញាណរបស់ពួកគេ ក្នុងការប្រឈមមុខជាមួយនឹងបញ្ហាទាំងនោះឡើយ។ ទោះបីជាពួកគេបានដឹងយ៉ាងជាក់ច្បាស់ អំពីអ្វីដែលព្រះគម្ពីរបានបង្រៀនទាក់ទងទៅនឹងបញ្ហាជំនឿ និង ចរិយាមារយាទក៏ដោយ ពួកគេនៅតែមិនពេញចិត្ត អនុវត្តតាមសេចក្ដីបង្រៀននេះឡើយ។ ពួកគេបានធ្វើឲ្យការសម្រេចចិត្តរួចជាស្រេច អំពីដំណោះស្រាយសម្រាប់បញ្ហារបស់ពួកគេ។ មិត្តភក្ដិគ្រិស្ដបរិស័ទជាច្រើនបានព្យាយាម បញ្ចុះបញ្ចូល ពួកគេឲ្យសម្រុះសម្រួលទំនាក់ទំនងរបស់ពួកគេ និង មិនធ្វើការលែងលះគ្នានោះទេ ប៉ុន្ដែពួកគេបានធ្វើការសម្រេចចិត្តរួចទៅហើយ ។ ពួកគេមិនចង់ឮពីអ្វីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ថ្លែងអំពីការលែងលះនោះទេ ព្រោះតែ នៅពេលដែលពួកគេឮពីរឿងនេះ វាអាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់ពួកគេ(សូមមើលនៅក្នុងគម្ពីរ ម៉ាកុស ១០:២-១២ និង គម្ពីរ ម៉ាថាយ៥:៣១-៣២)។ ពួកគេបានលែងលះគ្នា ភ្លាមៗ ហើយបានធ្វើឲ្យបញ្ហាមួយក្លាយទៅជាបញ្ហាកាន់តែធំ។

ដោយជ្រើសរើសយក មធ្យោបាយដោះស្រាយបញ្ហារបស់ពួកគេ ផ្ទុយទៅនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលបានបង្ហាញឲ្យឃើញនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ គូស្វាមីភរិយាវ័យក្មេងមួយគូនេះ បានផ្ដាច់ខ្លួនពួកគេចេញពីព្រះពរទាំងប៉ុន្មានខាងក្រោមនេះ៖

១. កម្លាំងដ៏អស្ចារ្យ ឆ្លងកាត់បញ្ហារបស់ពួកគេរហូតដល់ពេលដែលវាត្រូវបានដោះស្រាយ។
២. សន្តិភាពដែលបានមកពីការស្ដាប់បង្គាប់
៣. ការដឹកនាំដែលបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ត្រូវបានគេដឹងឮ។
៤. ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ក្នុងការផ្ដល់ចម្លើយដែលឥតព្រាងទុក និង អស្ចារ្យសម្រាប់បញ្ហា។

គូស្វាមីភរិយាទាំងពីរនាក់នេះ គឺជាឧទាហរណ៍នៃមនុស្សដែលមានចម្លើយខុសឆ្គងទៅកាន់សំណួរដ៏សំខាន់ពីរយ៉ាង ដែលខ្ញុំតែងតែសួរមកកាន់ខ្លួនឯង ហើយខ្ញុំចង់ចែកចាយជាមួយអ្នក ។ សំណួរនោះគឺ៖

១. តើខ្ញុំពិតជាចង់ដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់បញ្ហានេះដែរឬទេ?

២. ក្រោយពេលដែលខ្ញុំបានដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ហើយ តើខ្ញុំពិតជាចង់ធ្វើតាមដែរឬទេ ?

ប្រសិនបើ នៅពេលដែលអ្នកសួរសំណួរទាំងពីរនេះទៅកាន់ខ្លួនឯងហើយ អ្នកមិនអាចឆ្លើយថា បាទ/ចាស យ៉ាងច្បាស់ៗបានទេ នោះអ្វីដែលអ្នកត្រូវធ្វើដំបូងបំផុតគឺ ការចំណាយពេលរៀបចំវិញ្ញាណ ទូលសូមព្រះជាម្ចាស់ឲ្យទ្រង់ជួយអ្នកក្នុងការសម្រេចចិត្តនិយាយថា៖ "បាទ/ចាស ខ្ញុំចង់ស្វែងរក និង ធ្វើតាមដំណោះស្រាយរបស់ព្រះជាម្ចាស់សម្រាប់បញ្ហារបស់ខ្ញុំ។"

លំហាត់អនុវត្តន៍

១ ចូរប្រើប្រាស់អ្វីដែលអ្នកបានរៀននៅក្នុងមេរៀនទី១ និងទី២ មកឆ្លើយនឹងសំណួរទាំងនេះ៖

ក) ប្រាប់អំពីបញ្ហាដែលបានរៀបរាប់នៅក្នុងឧទាហរណ៍ដែលបានផ្តល់ជូននៅខាងលើ។

....

ខ) ប្រាប់អំពីប្រភពនៃបញ្ហា។

....

គ) ប្រសិនបើគូស្វាមីវ័យក្មេងនេះ ស្គាល់ពីបញ្ហាដ៏ពិតប្រាកដរបស់ពួកគេ និង ពីប្រភពរបស់វា ហើយទទួលស្គាល់វាផងនោះ តើអាចរកឃើញដំណោះស្រាយតាមសុភនិច្ឆ័យបែបណាដែល អាចនឹងជួយឲ្យពួកគេចូលទៅដោះស្រាយបញ្ហារបស់ពួកគេតាមរបៀបមួយដែរត្រឹមត្រូវ។

....

ការរៀបចំខាងឯវិញ្ញាណ

ការរៀបចំខាងឯវិញ្ញាណ គឺជារឿងដ៏មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការដោះស្រាយបញ្ហាឲ្យបានជោគជ័យ។ នៅក្នុងពេលដែលមាន ភាពតានតឹងគឺជាពេលដែលត្រូវបានបង្កើនការអធិស្ឋានថ្វាយបង្គំ និង ការអានព្រះគម្ពីរ វាមិនមែនជាពេលដែលត្រូវកាត់បន្ថយវានោះឡើយ។ ការដោះស្រាយបញ្ហាមួយនៅក្នុងរបៀបដូចជាព្រះគ្រិស្ត គឺមិនមែនជាអ្វីដែលយើងអាចសម្រេចចិត្តថានឹងធ្វើនៅក្នុងពេលដែលបញ្ហាកើតឡើងភ្លាមៗនោះទេ។ បញ្ហាអាចនឹងកើតឡើងមួយរំពេច ហើយត្រូវធ្វើអ្វីម្យ៉ាងភ្លាមៗ។ គ្រិស្តបរិស័ទដែលឈ្លាសវៃ នឹងរក្សាឥរិយាបថនៃភាពរួចរាល់ខាងឯវិញ្ញាណ រួមជាមួយនឹងដួងចិត្ត និងគំនិតរបស់ពួកគេបន្តបើកចំហសម្រាប់ការនាំផ្លូវពីព្រះវិញ្ញាណដ៏វិសុទ្ធ។

លោកសាវ័កបានផ្តល់ការណែនាំដ៏មានប្រយោជន៍ខ្លះៗ នៅក្នុងគម្ពីរ១ថេស្សាឡូនិក ៥:១៦-១៨, ២០-២២៖ "ចូរមានអំណរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាលៈទេសៈទាំងអស់ ....កុំមើលងាយការថ្លែងព្រះបន្ទូល ចូរពិចារណាមើលគ្រប់សេចក្តីទាំងអស់ ហើយស្រង់យកនូវសេចក្តីណាដែលល្អ។ ត្រូវចៀសចេញអោយផុតពីអំពើអាក្រក់គ្រប់បែបយ៉ាង។"

ការរៀបចំខាងវិញ្ញាណអាចមានរួមបញ្ចូលសកម្មភាពទាំងនេះ៖

១. មានពេលវេលាទៀងទាត់សម្រាប់ការអានព្រះគម្ពីរ ការរិះគិត (ការគិតពីអ្វីដែលអ្នកបានអាននោះ) និង ការអធិស្ឋានជារៀងរាល់ថ្ងៃ។ បើកចំហគំនិតរបស់អ្នកសម្រាប់អ្វីដែលព្រះគម្ពីរបង្រៀន។ អនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ ដឹកនាំគំនិតរបស់អ្នក។

២. ស្តាប់ការបង្រៀនបទបន្ទូល របស់គ្រូគង្វាល និង គ្រូបង្រៀនជាគ្រិស្តបរិស័ទផ្សេងទៀត។

៣. ការប្តេជ្ញានៅក្នុងចិត្តរបស់អ្នកថា ត្រូវគិតពីបញ្ហាទាំងអស់ទៅតាមអ្វីដែលព្រះគម្ពីរបង្រៀនអំពីវា ទោះបីជាដំណោះស្រាយតាមខគម្ពីរហាក់បីដូចជាពិបាកធ្វើតាមក៏ដោយ។

លំហាត់អនុវត្តន៍

២ សូមគិតពីបញ្ហាដែលអ្នកទើបតែនឹងមានថ្មីនេះ ឬ ធ្លាប់មានយូរមកហើយ។ ចូរវាយតម្លៃថាតើអ្នកបានរៀបចំវិញ្ញាណរបស់អ្នក ដើម្បីដោះស្រាយបញ្ហា និង ស្វែងរកបំណងព្រះហឫទ័យ របស់ព្រះជាម្ចាស់រួចជាស្រេចហើយ ឬ ក៏កំពុងតែរៀបចំនៅឡើយ។

		បាទ/ចាស	ទេ
ក)	ខ្ញុំចង់ដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទាក់ទងជាមួយនឹងបញ្ហានេះ។		
ខ)	ខ្ញុំធ្លាប់បានសិក្សាព្រះគម្ពីរដើម្បីដឹងថាតើព្រះជាម្ចាស់បានប្រទានការណែនាំពិសេស អំពីបញ្ហាមួយនេះ ឬ ស្ថានភាពស្រដៀងគ្នានេះដែរឬទេ។		
គ)	ខ្ញុំបានទូលសូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធនាំផ្លូវខ្ញុំដើម្បីឲ្យបានស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។		
ឃ)	ប្រសិនបើខ្ញុំត្រូវការជំនួយបន្ថែមដើម្បីស្វែងរកការណែនាំរបស់ព្រះជាម្ចាស់ចំពោះស្ថានភាពនេះ ខ្ញុំនឹងប្រឹក្សាជាមួយនឹងគ្រូគង្វាល ឬ មិត្តភក្តិគ្រិស្តបរិស័ទដែលឈ្លាសវៃម្នាក់។		
ង)	ខ្ញុំបានប្តេជ្ញាចិត្តស្តាប់បង្គាប់ព្រះជាម្ចាស់ និង ធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់ ទោះបីជាវាពិបាកសម្រាប់ខ្ញុំក៏ដោយ។		

ការរៀបចំខាងឯវិញ្ញាណទុកជាមុន នឹងជួយអ្នកឲ្យបានស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ផ្តល់កម្លាំងឲ្យអ្នក និង លើកទឹកចិត្តអ្នក ឲ្យប្រើប្រាស់ដំណោះស្រាយដ៏ល្អបំផុត និង រារាំងអ្នកមិនឲ្យធ្វើការសម្រេចចិត្តដែលអាចនាំឲ្យមានគ្រោះមហន្តរាយ។

ខ. ជៀសវាងការឆ្លើយតបដែលខុសឆ្គង

វត្ថុបំណងទី២. *ស្គាល់ពីការឆ្លើយតបខុសឆ្គងតាមរយៈឧទាហរណ៍ដែលបានផ្តល់ឲ្យ និង ធ្វើលំហាត់ផ្ទាល់ខ្លួន។*

ការរៀបចំខាងឯវិញ្ញាណ នឹងជួយអ្នកច្រានចោល និង ជៀសវាង របៀបដោះស្រាយស្ថានភាពបញ្ហាដែលមានលក្ខណៈទូលំទូលាយ តែខុសឆ្គងនោះ។ របៀបដែលខុសឆ្គងទាំងនេះ នឹងចូលទៅក្នុងចំណែកថ្នាក់ទាំងនេះ៖ កំហឹង, ការចុះចាញ់, និង ការខិតខំប្រឹងប្រែងរបស់មនុស្សតែមួយមុខ។ យើងនឹងពិចារណាសង្ខេបម្តងមួយៗ។

កំហឹង

មនុស្សជាច្រើនត្រូវបានគេធ្វើខុស ឬ បំពានលើ មានទំនោរចិត្តដំបូងថាត្រូវតែឆ្លើយតបជាមួយរបៀបដែលប្រកបដោយកំហឹង ឬ ឆេវឆាវ។ ការនេះអាចមានទម្រង់ជាច្រើនបែប៖ *កំហឹង* ដែលជះទៅលើអ្នកដទៃ ទៅលើព្រះជាម្ចាស់ ឬ ទៅលើកាលៈទេសៈរបស់យើង ; *ការចោទប្រកាន់* ឬស្តីបន្ទោសទៅលើអ្នកផ្សេងម្នាក់ទៀត និង សូម្បី *ការសងសឹក* ទៀតផង។ នៅពេលដែលយើងកំពុងតែឈឺចាប់ វាងាយណាស់ដែលយើងចង់ធ្វើបាបបុគ្គលម្នាក់ដែលធ្វើឲ្យយើងឈឺចាប់នោះ។ នេះមិនមែនជារបៀបដែលព្រះគ្រិស្តបង្រៀនឲ្យយើងឆ្លើយតបឡើយ ប៉ុន្តែវាក៏ជាកំហុសដែលកើតមានច្រើនដែរ។ របៀបរបស់ព្រះគ្រិស្តគឺដូចខាងក្រោមនេះ៖

> អ្នករាល់គ្នាធ្លាប់បានឮសេចក្តីថ្លែងទុកមកថា "ប្រសិនបើគេវាយភ្នែកអ្នកម្ខាង ត្រូវវាយភ្នែកគេតែម្ខាងវិញ ប្រសិនបើគេវាយអ្នកបាក់ធ្មេញមួយ ត្រូវវាយគេអោយបាក់ធ្មេញតែមួយដែរ"។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា កុំតបតនឹងមនុស្សកំណាចអោយសោះ បើមានគេទះ កំផ្លៀងស្ដាំរបស់អ្នក ចូរបែរអោយគេទះម្ខាងទៀតទៅ។....អ្នករាល់គ្នាធ្លាប់បានឮសេចក្តីថ្លែងទុកមកថា "ចូរស្រឡាញ់បងប្អូនឯទៀតៗ ហើយស្អប់ខ្មាំងសត្រូវរបស់អ្នក"។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ព្រមទាំងទូលអង្វរព្រះជា ម្ចាស់ សូមព្រះអង្គប្រទានពរអោយអស់អ្នកដែលបៀតបៀនអ្នករាល់គ្នាផង។ ធ្វើដូច្នេះ អ្នករាល់គ្នានឹងបានទៅជាបុត្ររបស់ព្រះបិតាដែលគង់នៅស្ថានបរមសុខ ។(គម្ពីរម៉ាថាយ ៥:៣៨-៣៩, ៤៣:៤៥)

ពិតណាស់ នៅពេលដែលយើងនាំឲ្យកំហឹងរបស់យើងទៅថ្វាយដល់ព្រះអម្ចាស់ យើងអាចទុកចិត្តថាទ្រង់នឹងថែរក្សាពួកយើង។ នៅក្នុងគម្ពីររ៉ូម ១២:១៩ លោកសាវ័កប៉ូលបានប្រាប់យើងថា "បងប្អូនជាទីស្រឡាញ់អើយ មិនត្រូវសងសឹកដោយខ្លួនឯងឡើយ គឺទុកអោយព្រះជាម្ចាស់សំដែងព្រះពិរោធចំពោះគេវិញ ដ្បិតមានចែងទុកមកថាៈ «ព្រះអម្ចាស់មានព្រះបន្ទូលថា "ការសងសឹកស្រេចតែលើយើង គឺយើងទេតើដែលនឹងតបទៅគេ"។

ព្រះគ្រិស្តគឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះមួយអំពីមនុស្សដែល "មិនចេះខឹង" នោះគឺមានន័យថា ទ្រង់មិនអនុញ្ញាតឲ្យអង្គទ្រង់ក្រោធឡើយ នៅពេលដែលមានគេធ្វើខុសមកលើទ្រង់។ ទ្រង់មិនដែល ឆ្លើយតបដោយកំហឹងនោះទេ។ នៅពេលដែលទ្រង់បានទតពីលើឈើឆ្កាងមក កាន់ទាហានរ៉ូម ដែលបានវាយទ្រង់ស្តោះទឹកមាត់ដាក់ទ្រង់ និង បានឆ្កាងទ្រង់នៅលើឈើឆ្កាងនោះ ទ្រង់បានអធិស្ឋានថា "ឱព្រះបិតាអើយ! សូមព្រះអង្គអត់ទោសអោយអ្នកទាំងនេះផង ដ្បិតគេមិនដឹងថាគេកំពុងធ្វើអ្វីឡើយ " (គម្ពីរលូកា២៣:៣៤) ។ នៅពេលដែលអ្នកមិនព្រមមានចិត្តខឹង ឬ ឆ្លើយតបដោយកំហឹង នៅពេលដែលនរណាម្នាក់ធ្វើខុសមកលើអ្នក អ្នកនឹងទទួលបានអំណរដ៏ពិតដែលដឹងថា អ្នកបានឆ្លងកាត់បញ្ហានោះ ដោយឥរិយាបថត្រឹមត្រូវ។ ការនេះពង្រឹងកម្លាំងអ្នក ដើម្បីនៅពេលដែលមានការបំពានមួយទៀតមកដល់ វានឹងមានភាពងាយស្រួលក្នុងការប្រឈមមុខជាមួយវាដោយគ្មានកំហឹង។

"ការមិនចេះខឹង" ទាមទារការអធិស្ឋាននិង ការអនុវត្ត ប៉ុន្តែវានឹងជាព្រះពរមួយនៅពេលដែលយើងអាចក្រឡេកមើលមកក្រោយវិញ ហើយអាចនិយាយថា " ខ្ញុំរីករាយណាស់ដែលខ្ញុំមិនបានឆ្លើយតបដោយកំហឹង ផ្ទុយទៅវិញខ្ញុំអាចបង្ហាញក្តីស្រឡាញ់ ទៅកាន់បុគ្គលដែលព្យាយាមបៀតបៀនខ្ញុំ"។

លំហាត់អនុវត្តន៍

៣ ចូរផ្គូផ្គង ការឆ្លើយតបដែលនៅក្នុងជួរខាងស្តាំ ទៅជាមួយនឹង ការរៀបរាប់អាកប្បកិរិយារបស់វានៅក្នុងជួរខាងឆ្វេង។ ចូរសរសេរអក្សរនៃជម្រើសរបស់អ្នក នៅក្នុងចន្លោះបន្ទាត់នីមួយៗ។

........ក)	"វាគឺជាកំហុសរបស់គាត់ដែលខ្ញុំមិនទទួលបានការងារនោះ។ គាត់ពិតជាមានបំណងរារាំងខ្ញុំមិនឲ្យទទួលបានវា"	១)	កំហឹង
		២)	ការចោទប្រកាន់
........ខ)	"រឿងចុងក្រោយដែលខ្ញុំចង់ធ្វើ គឺជម្រះបញ្ជីជាមួយគេ!"	៣)	ទាស់ចិត្ត
........គ)	"នាងបានធ្វើឲ្យខ្ញុំឈឺចាប់ខ្លាំងណាស់ ខ្ញុំនឹងមិននិយាយជាជាមួយនាងទៀតទេ!"	៤)	ការសងសឹក
........ឃ)	"ខ្ញុំបានប្រាប់នាងត្រង់ៗនូវអ្វីដែលខ្ញុំគិត អំពីចរិតកោងកាច និង អាក្រក់របស់នាង។		

ការចុះចាញ់

ការចុះចាញ់ ឬ ការដកថយ អាចមានជាច្រើនទម្រង់។ ពេលខ្លះវាមានន័យថា ការរត់គេចពីបញ្ហា ឬ រកកន្លែងលាក់ខ្លួន។ អ្នកខ្លះ រត់គេចពីការពិតដោយ លង់ខ្លួនទៅក្នុងការញៀនថ្នាំ ការប្រមឹកស្រា ការស្វែងរកការសប្បាយបែបលោកីយ៍ ការបរិភោគច្រើន ឬ ការធ្វើការច្រើន ភាពងុបងល់ក្នុងសាសនា ឬ មធ្យោបាយជាច្រើនទៀត។ អ្នកស្ទើរតែអាចលាក់ខ្លួននៅពីក្រោយអ្វីៗគ្រប់បែបយ៉ាងដើម្បីចង់គេចពីការប្រឈមមុខជាមួយនឹងសេចក្ដីពិត។ (ពិតណាស់ វាក៏មានការដកថយដែលមានប្រយោជន៍មួយដែរ គឺនៅពេលដែលគ្រិស្តបរិស័ទម្នាក់ បានជ្រើសរើសយកការដើរចេញពីស្ថានការណ៍នោះដើម្បី *ជៀសវាង* បញ្ហា)។

ពេលខ្លះ ការចុះចាញ់អាចមានលក្ខណៈជាការរត់គេចខ្លួន។ ខ្ញុំស្គាល់ស្ត្រីវ័យក្មេងម្នាក់ដែលមិនទាន់រៀបការនៅឡើយ ហើយកំពុងរស់នៅជាមួយឪពុកម្ដាយរបស់នាង។ នាងចាប់ផ្ដើមព្រួយបារម្ភថានាងនឹងមិនបានរៀបការ និង ត្រូវមានទំនួលខុសត្រូវ ក្នុងការមើលថែឪពុកម្ដាយដែលមានវ័យចំណាស់របស់នាង ស្របពេលដែលប្អូនប្រុស និង ប្អូនស្រីរបស់នាងដែលបានរៀបការហើយ គេមិនមានទំនួលខុសត្រូវនោះឡើយ។ មិនយូរប៉ុន្មាន នាងមានអារម្មណ៍ថា ស្រណោះខ្លួន និង មានភាពល្វីងជូរចត់ ដែលធ្វើឲ្យនាងសម្រេចចិត្តរៀបចំរបស់របររបស់នាង ហើយចាកចេញពីផ្ទះដោយមិនប្រាប់នរណាម្នាក់ឲ្យដឹងថានាងទៅកន្លែងណានោះទេ។

លក្ខណៈមួយទៀតនៃការចុះចាញ់គឺជាការ *ដកថយ* ។ មានស្ត្រីមេម៉ាយម្នាក់ដែលខ្ញុំស្គាល់ នាងមិនព្រមចេញពីផ្ទះរបស់នាងទាល់តែសោះ លើកលែងតែមានគ្រោះអាសន្នបន្ទាន់ ហើយនាងឈប់ទៅជួបគ្រួសារ និង មិត្តភក្តិរបស់នាងទៀត តាំងពីពេលដែលប្ដីរបស់នាងបានទទួលមរណៈភាពបាត់ទៅ។ នាងពិតជាឯកា និង ក្រៀមក្រំខ្លាំងណាស់។

លំហាត់អនុវត្តន៍

៤ តើឥរិយាបថណាខ្លះ នៅខាងក្រោមនេះ ដែលអ្នកឃើញមាននៅក្នុងមនុស្សដែលព្យាយាមរត់គេច ពីបញ្ហារបស់ពួកគេ ដោយការចុះចាញ់ និង ការដកថយ?

ក) ភាពមិនអាត្មានិយម

ខ) ភាពអាត្មានិយម

គ) ស្រណោះខ្លួន

ឃ) អំណរ

ង) សេចក្ដីសង្ឃឹម

ច) ភាពល្វីងជូរចត់

ឆ) កំហឹង

៥ ចូរឆ្លើយសំណួរខាងក្រោមដោយ គូសគ្រីស ត្រង់ប្រអប់ *បាទ/ចាស* ឬ *ទេ។*

		បាទ/ចាស	ទេ
ក)	នៅពេលដែលរឿងរ៉ាវមិនស្របទៅតាមអ្វីដែលអ្នកចង់បាន តើអ្នកតែងតែឆ្លើយតបដោយកំហឹងមែនឬទេ?		
ខ)	នៅពេលដែលមានបញ្ហាកើតឡើង តើអ្នកព្យាយាមបន្ទោសវាទៅលើអ្នកដទៃ ទោះបីវាជាកំហុសរបស់អ្នកក៏ដោយមែនដែរឬទេ?		
គ)	តើមនុស្សតែងតែបំពានលើអ្នក មែនឬទេ?		
ឃ)	តើអ្នកមានអារម្មណ៍តូចចិត្ត និង អវិជ្ជមានជាញឹកញាប់មែនឬទេ?		
ង)	ប្រសិនបើមាននរណាម្នាក់ធ្វើខុសមកលើអ្នក តើអ្នកគឺជាប្រភេទមនុស្សដែលមិនអាចនៅស្ងៀមបាន លុះត្រាតែអ្នកបានធ្វើអ្វីម្យ៉ាងដើម្បី សងសឹកគេវិញ មែនឬទេ?		
ច)	តើអ្នកធ្លាប់បានព្យាយាមចុះចាញ់ និង ដកខ្លួនចេញពីស្ថានភាពលំបាក ដោយមិនប្រឈមមុខជាមួយវាតាមរបៀបវិជ្ជមាន ដែរឬទេ?		

ការខិតខំប្រឹងប្រែងរបស់មនុស្សតែមួយមុខ

វត្ថុបំណងទី៣. *បកស្រាយថា ហេតុអ្វីបានជាវាមានសារៈសំខាន់ម្ល៉េះ ដែលមិនត្រូវព្យាយាមដោះស្រាយបញ្ហារបស់អ្នក ដោយសមត្ថភាពមនុស្សតែម្យ៉ាងនោះ។*

ខ្ញុំបានទុកការឆ្លើយតបដោយការជួយខ្លួនឯងនេះនៅក្រោយគេ ព្រោះវាមិនសុទ្ធតែអវិជ្ជមានទាំងអស់នោះទេ។ ព្រះជាម្ចាស់បានបង្កើតបំណងចិត្តរបស់មនុស្ស ឲ្យជាកម្លាំងវិជ្ជមានមួយដែលអាចឡើងផុតពីការលំបាកនៅក្នុងជីវិតតាមរបៀបដ៏អស្ចារ្យមួយ។ ប្រសិនបើគ្មានឫទ្ធានុភាពនៅក្នុង "ការគិតវិជ្ជមាន" នោះទេ អ្នកដែលមិនមែនជាគ្រិស្តបរិស័ទ មិនអាចនឹងមានជីវិតរស់បានឡើយ។ ប៉ុន្តែការទុកចិត្តទៅលើអំណាចឆន្ទៈរបស់មនុស្សថាជាធនធានចម្បងនៅក្នុងការដោះស្រាយ បញ្ហាជីវិត គឺមិនមែនជារបៀបរបស់គ្រិស្តបរិស័ទនោះទេ! បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺដើម្បីឲ្យបុត្រាបុត្រីរបស់ទ្រង់ ប្រឈមមុខជាមួយនឹងបញ្ហា ដោយឫទ្ធានុភាពដែលបានប្រោសព្រះគ្រិស្តឲ្យមានព្រះជន្មរស់នោះ ហើយដើម្បីឲ្យពួកគេប្រើប្រាស់បញ្ហារបស់ពួកគេទុកជាឱកាសសម្រាប់ទ្រង់បង្ហាញពីឫទ្ធានុភាព និង ព្រះគុណរបស់ទ្រង់។ ដូច្នេះ នៅក្នុងការជ្រើសរើសការឆ្លើយតបដើម្បីជៀសវាងបញ្ហា វាពិតជាមានសារៈសំខាន់ណាស់ដែលអ្នក *មិនត្រូវ* ព្យាយាមដោះស្រាយបញ្ហាដោយការខិតខំប្រឹងប្រែងរបស់មនុស្សតែមួយមុខនោះឡើយ ប៉ុន្តែត្រូវយកវាទៅថ្វាយព្រះជាម្ចាស់ដោយការអធិស្ឋានវិញ។

គ្មានបញ្ហាណាមួយដែលតូចពេក ក្នុងការនាំទៅថ្វាយព្រះអម្ចាស់នោះទេ។ នៅពេលដែលខ្ញុំកំពុងបើកឡានរបស់ខ្ញុំ ហើយខ្ញុំគ្មានពេលវេលាគ្រប់គ្រាន់ ជាមួយនឹងការងារជាច្រើនដែលខ្ញុំត្រូវធ្វើ ដល់ថ្នាក់ខ្ញុំអធិស្ឋានសម្រាប់កន្លែងចតឡានទៀតផង។ តើនេះគឺជារឿងឆោតល្ងង់ដែរឬទេ? អត់ទេ! ព្រះជាម្ចាស់គឺជាព្រះអាទិករដ៏ធំអស្ចារ្យនៃចក្រវាឡ ប៉ុន្តែទ្រង់ក៏ជាព្រះដែលជ្រាប សូម្បីនៅពេលណាដែលមានកូនចាបធ្លាក់ទៅលើដី និង ជាព្រះដែលអាចរាប់សរសៃសក់នៅលើក្បាលរបស់អ្នកអស់ផងដែរ (គម្ពីរម៉ាថាយ ១០:២៩-៣១) ។ ទ្រង់ក៏យកព្រះទ័យទុកដាក់ចំពោះបញ្ហាដែលតូចតាចបំផុតនៅក្នុងជីវិតរបស់អ្នក ហើយទ្រង់សព្វព្រះទ័យជួយអ្នកផងដែរ។ ដូច្នេះហើយ រឿងដែលសំខាន់បំផុតដែលអ្នកអាចធ្វើ ចំពោះការដោះស្រាយបញ្ហានៅក្នុងជីវិត គឺត្រូវដើរតាមការបង្គាប់របស់អ្នកនិពន្ធក្នុងគម្ពីរ សុភាសិត ៣:៥-៨។ ចូរអានខគម្ពីរនេះបន្ទាប់មកជ្រើសរើសចម្លើយសម្រាប់សំណួរខាងក្រោមនេះ។

លំហាត់អនុវត្តន៍

៦ សុភាសិតនេះប្រាប់អ្នក ឲ្យជឿលើ

ក) អ្វីដែលអ្នកគិតថាអ្នកដឹង

ខ) ព្រះអម្ចាស់

៧ សុភាសិតនេះក៏បានប្រាប់អ្នក មិនឲ្យផ្អែកលើ

ក) អ្នកដទៃ

ខ) ការយល់ដឹងរបស់អ្នកផ្ទាល់ (អ្វីដែលអ្នកគិតថាអ្នកដឹង)

គ) អារម្មណ៍របស់អ្នក។

៨ ប្រសិនបើអ្នកចងចាំពីព្រះអម្ចាស់(ទទួលស្គាល់ទ្រង់) នៅក្នុងគ្រប់អ្វីៗទាំងអស់ដែលអ្នកធ្វើ អ្នកអាចរំពឹងក្នុងចិត្តបាន ថាទ្រង់នឹង

ក) បង្ហាញអ្នកពីផ្លូវត្រឹមត្រូវដែលត្រូវដើរ។

ខ) ប្រទានឲ្យអ្នកមានបញ្ហាតែបន្តិចបន្តួចតែប៉ុណ្ណោះ។

នៅពេលដែលអ្នកយកបញ្ហាតូចតាចទៅថ្វាយព្រះជាម្ចាស់ វាប្រហែលមានភាពងាយស្រួលជាងការដែលត្រូវទុកចិត្តលើទ្រង់នៅពេលអ្នកប្រឈមមុខជាមួយនឹងបញ្ហាដែលហាក់បីដូចជាគ្មានដំណោះស្រាយទាល់តែសោះនោះ។ នេះគឺជាឱកាសរបស់ព្រះជាម្ចាស់ ដើម្បីធ្វើការអស្ចារ្យនៅក្នុងជីវិតរបស់អ្នក អំណាចរបស់ទ្រង់គឺគ្មានដែនកំណត់ឡើយ នៅពេលដែលអ្នករៀនទុកចិត្តអ្វីៗគ្រប់បែបយ៉ាងនៅក្នុងព្រះហស្តរបស់ទ្រង់ ហើយទ្រង់នឹងមិនធ្វើឲ្យអ្នកខកបំណងឡើយ! (សូមមើលគម្ពីរអេភេសូ ៣:២០ និង គម្ពីរ១យ៉ូហាន ៥:១៤-១៥)។

លំហាត់អនុវត្តន៍

៩ ហេតុអ្វីបានជា វាមានសារៈសំខាន់ដែលមិនត្រូវ ដោះស្រាយបញ្ហារបស់អ្នក ដោយប្រើសមត្ថភាពរបស់មនុស្សតែមួយមុខនោះ?

....

....

....

គ. ប្រើប្រាស់វិធីសាស្ត្របែបប្រព័ន្ធ

វត្ថុបំណងទី៤. *ធ្វើតារាងតាមដានមួយ ដើម្បីតាមដានការដោះស្រាយស្ថានភាពរបស់បញ្ហា ដោយផ្អែកលើវិធី សាស្ត្រដែលបានផ្តល់ឲ្យ និង ដាក់តារាងតាមដាននោះទៅលើបញ្ហាដែលបានផ្តល់ឲ្យ។*

យើងបានចាក់គ្រឹះ ជាយូរមកហើយនៅក្នុងមេរៀននេះ សម្រាប់ការប្រើប្រាស់វិធីសាស្ត្របែបប្រព័ន្ធក្នុងការដោះស្រាយបញ្ហា ដោយផ្អែកលើគោលការណ៍របស់គ្រិស្តបរិស័ទ។ មានសៀវភៅជាច្រើន ត្រូវបានគេសរសេរឡើង ដើម្បីជួយមនុស្សដែលមានបញ្ហាគ្រប់ប្រភេទ។ នេះគឺជា មុខវិជ្ជាដ៏ស្មុគស្មាញមួយ ហើយមានមធ្យោបាយជាច្រើនសម្រាប់ការដោះស្រាយបញ្ហានោះ។ គោលបំណងរបស់យើងគឺ ចង់ផ្តល់ជូនអ្នកនូវការណែនាំខ្លះ ដែលនឹងជួយអ្នកឲ្យប្រឈមមុខជាមួយនឹងបញ្ហារបស់អ្នក ដោយឥរិយាបថត្រឹមត្រូវ និងវិញ្ញាណមួយដែលដូចជាព្រះគ្រិស្ត ប្រសិនបើអ្នកដើរតាមការណែនាំនោះមែន ហើយអនុញ្ញាតឲ្យព្រះជាម្ចាស់ប្រទានចម្លើយសម្រាប់បញ្ហានោះ។

បន្ទាប់ពីយើងបានពិភាក្សា ជំហានជាមូលដ្ឋានទាំងប្រាំមួយ នៅក្នុងវិធីសាស្ត្រជាប្រព័ន្ធនៃការដោះស្រាយបញ្ហានេះ យើងនឹងផ្តល់ឱកាសឲ្យអ្នក ស្វែងរកពីជំហានទាំងនោះ ដោយប្រើប្រាស់ស្ថានភាពបញ្ហាមួយដែលនៅក្នុងបទគម្ពីរ និង មួយទៀតដែលមាននៅក្នុងស្ថានភាពបច្ចុប្បន្ននេះ។ ដោយយើងនឹងពិភាក្សាអំពីបញ្ហាជាក់លាក់ នៅក្នុងមេរៀនក្រោយៗទៀត អ្នកនឹងមានឱកាស អនុវត្តជំហានទាំងនេះ ដើម្បីធ្វើការសម្រេចចិត្តចំពោះបញ្ហានៅក្នុងព្រះគម្ពីរ។ យើងខ្ញុំសង្ឃឹមថា ដោយធ្វើដូច្នេះ នឹងជួយអ្នកឲ្យធ្វើការអនុវត្តគោលការណ៍ទាំងនេះ នៅក្នុងបញ្ហាជាក់ស្តែងនៅក្នុងជីវិតរបស់អ្នកផ្ទាល់ ឬ នៅក្នុងជីវិតរបស់អ្នកដទៃដែលអ្នកចង់ជួយ។

<table>
<tr><th colspan="2">ជំហានឆ្ពោះទៅរកការដោះស្រាយបញ្ហា</th></tr>
<tr><th>វិធីសាស្ត្រ ក</th><th>វិធីសាស្ត្រ ខ</th></tr>
<tr><td>១. ស្គាល់បញ្ហា
ក. ស្គាល់ប្រភព
ខ. ស្វែងរកប្រភពដែលស៊ីជម្រៅជាងនេះ
២. ថ្វាយបញ្ហារបស់អ្នកទៅកាន់ព្រះជាម្ចាស់។
៣. គិតអំពីដំណោះស្រាយទាំងអស់ដែលអាចមាន នៅក្រោមការបំភ្លឺពីសេចក្តីបង្រៀនរបស់បទគម្ពីរ។ (ចូរប្រើធនធានរបស់អ្នក)
៤. គិតអំពីផលវិបាកនៃជម្រើសទាំងអស់ ដែលអាចកើតមាន។ (ចូរប្រើធនធានរបស់អ្នក)
៥. ជ្រើសយកដំណោះស្រាយមួយ ហើយយកវាទៅប្រើប្រាស់។
៦. វាយតម្លៃទៅលើលទ្ធផល ដែលបានមកពីដំណោះស្រាយរបស់អ្នក និង ធ្វើការកែតម្រូវផ្សេងៗដែលមាន។</td><td>(សម្រាប់បញ្ហាដែលហាក់បីដូចជាគ្មានដំណោះស្រាយ ភ្លាមៗ)
១. ស្គាល់បញ្ហា។
២. ថ្វាយបញ្ហានោះទៅ កាន់ព្រះជាម្ចាស់។
៣. រំពឹងថាព្រះជាម្ចាស់ធ្វើការដើម្បីប្រយោជន៍ របស់អ្នក។</td></tr>
</table>

វិធីសាស្ត្រ ក

ជំហានទី១ ស្គាល់បញ្ហា

មានបញ្ហាខ្លះ យើងមិនអាចស្គាល់វាបាន ដោយងាយៗនោះឡើយ។ តែមានខ្លះទៀត យើងអាចស្គាល់បានយ៉ាងងាយ។ ឧបមាថា ខ្ញុំត្រូវការលុយ ឬមានអ្នកជិតខាងដែលខ្ញុំមិនចូលចិត្ត ឬ ខ្ញុំសំគាល់ឃើញថា ភ្នែករបស់ខ្ញុំកាន់តែខ្សោយទៅៗ។ បញ្ហាប្រភេទនេះ ងាយសំគាល់ឃើញណាស់។

ប៉ុន្តែ ប្រសិនបើ ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្ត តែមិនដឹងមូលហេតុអ្វី ឬ គេងមិនលក់ ឬ មានអារម្មណ៍ថា មិនស្រណុកចិត្ត តែមិនអាចបកស្រាយបាន ថាបញ្ហានេះមកពីមូលហេតុអ្វី នោះខ្ញុំត្រូវតែធ្វើការសង្រួមចិត្ត និង អធិស្ឋានជាពិសេសមួយ ដើម្បីរកឃើញប្រភពនៃបញ្ហាទាំងនោះ។ ខ្ញុំប្រហែលជាត្រូវការជំនួយពីខាងក្រៅ ដើម្បីរកប្រភពបញ្ហានោះផងដែរ។

ទីមួយ អ្នកត្រូវតែ*ស្គាល់ពី ប្រភពរបស់បញ្ហា*។ យើងបានរៀនរួចមកហើយ អំពីប្រភពនៃបញ្ហានៅក្នុងមេរៀនទី១។ នៅពេលណាដែល អ្នកបានស្គាល់ពីប្រភពបញ្ហានេះហើយ អ្នកនឹងអាចប្រឈមមុខជាមួយនឹងបញ្ហានោះបាន។ នៅពេលដែលអ្នកឃើញថាវា ជារឿងដែលអាចនឹងធ្វើការផ្លាស់ប្តូរបាន នោះអ្នកអាចឈានទៅកាន់ជំហានបន្ទាប់ទៀតបាន។

ទីពីរ អ្នកប្រហែលជាត្រូវ *រកមើលមូលហេតុស៊ីជម្រៅជាងនេះ*។ ឧបមាថា ខ្ញុំខ្វះលុយសម្រាប់ទិញអាហារបរិភោគ ហើយប៉ុន្មានថ្ងៃទៀត ខ្ញុំក៏នឹងមិនទាន់ទទួលបានប្រាក់ខែរបស់ខ្ញុំដែរ ។វាប្រហែលមកពី ខ្ញុំមិនបានប្រុងប្រយ័ត្នចំពោះលុយរបស់ខ្ញុំ ហើយបានប្រើប្រាស់វាជាមួយរបស់ដែលមិនចាំបាច់ ។ ខ្ញុំអាចដោះស្រាយបញ្ហានេះបានយ៉ាងងាយ ដោយរៀបចំផែនការដោយប្រុងប្រយ័ត្ន នៅថ្ងៃមុខ ប៉ុន្តែប្រសិនបើខ្ញុំមើលឃើញថា តម្រូវការចាំបាច់ក្នុងជីវិតរបស់ខ្ញុំច្រើនជាង ចំណូលប្រចាំសប្តាហ៍របស់ខ្ញុំដែលអាចផ្គត់ផ្គង់

សម្រាប់តម្រូវការប្រចាំថ្ងៃនោះ ខ្ញុំត្រូវតែស្វែងរកដោះស្រាយដែលមានស្ថេរភាពជាងនេះ។ មូលហេតុស៊ីជម្រៅនោះគឺ ខ្ញុំត្រូវការលុយដើម្បីចំណាយសម្រាប់តម្រូវការចាំបាច់របស់ខ្ញុំច្រើនជាង អ្វីដែលខ្ញុំអាចរកបាន។ ខ្ញុំត្រូវតែ បង្កើនចំណូលរបស់ខ្ញុំ ឬ ត្រូវកាត់បន្ថយចំណាយរបស់ខ្ញុំ។

លំហាត់អនុវត្តន៍

១០ ចូរបង្កើតតារាងមួយនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ហើយសរសេរសំណួរដែល អ្នកអាចប្រើប្រាស់នៅក្នុងការដោះស្រាយបញ្ហា។ អ្នកនឹងត្រូវសរសេរសំណួរបន្ថែមទៀត នៅពេលដែលអ្នកបន្តសិក្សាផ្នែកមួយនេះ។ ចូររំឭកជំហានទី១ម្តងទៀត ហើយសាកល្បងសរសេរ បី ឬ បួនសំណួរដើម្បីជួយអ្នកក្នុងការដើរតាមជំហានមួយនេះ។ ក្រោយពីបានសរសេរសំណួររបស់អ្នកហើយ ចូរផ្ទៀងផ្ទាត់សម្រាប់ចម្លើយរបស់ខ្ញុំ នៅចុងបញ្ចប់មេរៀននេះ ។

ជំហានទី២ ថ្វាយបញ្ហារបស់អ្នកទៅកាន់ព្រះជាម្ចាស់

ព្រះជាម្ចាស់ជាព្រះដែលធំជាងបញ្ហាគ្រប់បែបយ៉ាងដែលអ្នកមាន។ សូមក្រឡេកចេញពីបញ្ហារបស់អ្នក ហើយសំឡឹងទៅមើល ព្រះដែលជ្រាបគ្រប់ការទាំងអស់ ដែលមានប្រាជ្ញាលើសអ្វីទាំងអស់ ដែលមានក្តីស្រឡាញ់លើសគេ និង ជាព្រះដ៏មានឫទ្ធានុភាពលើសអ្វីគ្រប់យ៉ាង គឺព្រះយេស៊ូគ្រិស្ត។ ទ្រង់ខ្វល់ព្រះទ័យចំពោះអ្នក (គម្ពីរ ១ពេត្រុស ៥:៧) ។ ចូរនិយាយអំពីបញ្ហាថ្វាយទៅកាន់
ព្រះជាម្ចាស់។ នោះគឺជាការនិយាយចេញមកឲ្យឮៗដោយពាក្យរបស់អ្នកផ្ទាល់។ ព្រះជាម្ចាស់ជ្រាបហើយថា បញ្ហានោះជាអ្វី ប៉ុន្តែទ្រង់សព្វព្រះហឫទ័យឲ្យយើងចូលទៅរកទ្រង់តាមរយៈការអធិស្ឋាន។

ការអធិស្ឋានប្រកបដោយភាពជាក់លាក់ ពិតជាមានសារៈសំខាន់ណាស់។ ខ្ញុំស្គាល់ស្ត្រីដែលជាគ្រិស្តបរិស័ទម្នាក់ គាត់បានកត់ត្រាសំណូមពរអធិស្ឋានរបស់គាត់ ព្រមទាំងបានកត់ត្រាថ្ងៃដែលគាត់ចាប់ផ្តើមអធិស្ឋានសម្រាប់សំណូមពរនីមួយៗ។ ក្រោយមកទៀត នៅពេលដែលមានការឆ្លើយតប គាត់បានតត់ត្រាថ្ងៃនោះទុកផងដែរ។ គាត់និយាយថា នៅពេលដែលគាត់បើកមើលកំណត់ត្រា វាបានជួយពង្រឹងជំនឿរបស់គាត់ ហើយឲ្យគាត់ឃើញថា ព្រះជាម្ចាស់ស្មោះត្រង់យ៉ាងណា។ ការធ្វើដូច្នេះ ក៏ជួយរំឭកគាត់ឲ្យអរព្រះគុណព្រះជាម្ចាស់សម្រាប់សេចក្តីអធិស្ឋានដែលទទួលបានការឆ្លើយតបទាំងនោះផងដែរ។

នៅពេលដែលអ្នកបាន បង្វែរគំនិតចេញពីបញ្ហារបស់អ្នកទៅរកព្រះអម្ចាស់ អ្នកនឹងមានអារម្មណ៍ថាមានបន្ទុកយ៉ាងធ្ងន់មួយបានរអិលចេញពីស្មារបស់អ្នក។ ការព្រួយបារម្ភត្រូវតែចេញឆ្ងាយពីអ្នក ព្រោះអ្នកទុកចិត្តលើព្រះគ្រិស្ត។ បន្ទុក ក៏ត្រូវចេញពីអ្នក ព្រោះទ្រង់មានបន្ទូលថា "អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់អើយ! ចូរមករកខ្ញុំ ខ្ញុំនឹងអោយអ្នករាល់គ្នាបានសំរាក។" (គម្ពីរម៉ាថាយ ១១:២៨)។ " ចូរផ្ទេរទុក្ខកង្វល់ទាំងប៉ុន្មានរបស់បងប្អូនទៅព្រះអង្គទៅ ដ្បិតទ្រង់យកព្រះហឫទ័យទុកដាក់នឹងបងប្អូន។" (គម្ពីរ ១ពេត្រុស ៥:៧)។ នេះគឺជា និយមន័យពិតប្រាកដនៃការប្តេជ្ញា៖ ការខ្វល់ខ្វាយ គ្រប់គ្រាន់នឹងជំរុញឲ្យ ធ្វើអ្វីដែលគួរធ្វើ និង ការជឿទុកចិត្ត ដែលដកការព្រួយបារម្ភ និងភាពភ័យខ្លាចឲ្យចេញឆ្ងាយ។

លំហាត់អនុវត្តន៍

១១ ចូរសរសេរបន្ថែមសំណួរទីប្រាំ ទៅក្នុងតារាងរបស់អ្នក ដោយយោងតាមជំហានទី២។

ជំហានទី៣ គិតអំពីដំណោះស្រាយទាំងអស់ដែលអាចមាន

យើងបានពិភាក្សាគ្នារួចមកហើយនៅក្នុងមេរៀនទី ២ អំពីរបៀបស្វែងរកដំណោះស្រាយ។ មានពេលខ្លះ ក៏មានដំណោះស្រាយជាច្រើន សម្រាប់បញ្ហាតែមួយ។ អ្វីដែលអ្នកគួរធ្វើ គឺស្វែងរកដំណោះស្រាយដែល*ល្អបំផុត*។ សូមអនុវត្តជំហានទាំងនេះ សម្រាប់គ្រប់ដំណោះស្រាយទាំងអស់ដែលមាន។

១. ស្វែងរកគោលការណ៍តាមបទគម្ពីរ ដែលយកទៅអនុវត្តនៅក្នុងបញ្ហានោះបាន។ ច្រានចោលដំណោះស្រាយទាំងឡាយណាដែលមិន ដើរតាមគោលការណ៍នៃព្រះគម្ពីរ។

២. ស្វែងរកចម្លើយនៅក្នុងកន្លែងដែលសមរម្យ (ត្រឹមត្រូវ) ។ ចូរប្រើប្រាស់ធនធានរបស់អ្នក។ (សូមមើលមេរៀនទី២)

៣. ស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

លំហាត់អនុវត្តន៍

១២ សូមសរសេរបន្ថែមសំណួរទី ៦ ដល់ទី៨ ទៅក្នុងតារាងរបស់អ្នក ដោយផ្អែកលើជំហានទី៣ នេះ។ អ្នកត្រូវសរសេរសំណួររបស់អ្នកសិន មុនពេលដែលអ្នកទៅមើលសំណួរដែលខ្ញុំបានសរសេរ។ ធ្វើដូច្នេះ នឹងជួយអ្នកឲ្យចងចាំអ្វីដែលអ្នកបានរៀន។

ជំហានទី៤ គិតអំពីផលវិបាកនៃជម្រើសទាំងអស់ ដែលអាចកើតមាន

សូមគិតពីផលវិបាកដែលអាចកើតមាន ចំពោះគូស្វាមីភរិយាដែលបានសម្រេចចិត្តថា ការលែងលះគ្នាគឺជាដំណោះស្រាយសម្រាប់បញ្ហារបស់ពួកគេ។ លទ្ធផលនៃគ្រួសារដែលបែកបាក់ មិនត្រឹមតែជះឥទ្ធិពលដល់ ប្តី និង ប្រពន្ធនោះឡើយ ប៉ុន្តែក៏ជះឥទ្ធិពលដល់កូនៗផងដែរ។ ដំណោះស្រាយដែលខុសមួយ វាអាចបង្កើតឲ្យមានបញ្ហាធំជាង បញ្ហាដើមដំបូងទៅទៀត។ នោះជាមូលហេតុដែល វាជារឿងសំខាន់ណាស់ ក្នុងការច្រានចោលដំណោះស្រាយណា ដែលមិនស្របតាមការបង្រៀនរបស់បទគម្ពីរ។ ចូរប្រើប្រាស់ធនធានរបស់អ្នកដើម្បីធ្វើការកំណត់ ផលវិបាកអ្វីដែលអាចជាលទ្ធផលដែលបានមកពីការសម្រេចចិត្តរបស់អ្នក។

លំហាត់អនុវត្តន៍

១៣ ចូរសរសេរបន្ថែមសំណួរទី ៩ ទៅក្នុងតារាងរបស់អ្នកដោយផ្អែកលើជំហានទី៤។ សូមគិតពិចារណាពីតម្លៃដ៏អស់កល្បជានិច្ចនៃការសម្រេចចិត្តរបស់អ្នក ក៏ដូចជាតម្លៃក្នុងពេលបច្ចុប្បន្ននៅលើលោកីយ៍នេះផងដែរ។

ជំហានទី៥ : ជ្រើសយកដំណោះស្រាយមួយ ហើយយកវាទៅប្រើប្រាស់។

អ្នកបានស្គាល់បញ្ហារបស់អ្នកហើយ អ្នកក៏បានថ្វាយបញ្ហានោះទៅកាន់ព្រះជាម្ចាស់ដោយការអធិស្ឋានដែរ។ អ្នកបានសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងយកចិត្តទុកដាក់ ដើម្បីស្វែងរកសេចក្ដីបង្រៀនរបស់ទ្រង់ដែលទាក់ទងនឹងបញ្ហារបស់អ្នក ឬ បញ្ហាផ្សេងៗទៀតផងដែរ។ បើចាំបាច់ អ្នកត្រូវពិភាក្សាបញ្ហាអ្នកជាមួយនឹងមិត្តភក្តិដែលជាគ្រិស្តបរិស័ទ គ្រូគង្វាល ឬ អ្នកប្រឹក្សាយោបល់ផងដែរ។ អ្នកបានប្រើប្រាស់ការវិនិច្ឆ័យដ៏ល្អបំផុតរបស់អ្នក អ្នកត្រូវបានដឹកនាំដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីធ្វើការសម្រេចចិត្តថា បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្រាប់អ្នកនៅក្នុងស្ថានភាពនោះ ជាអ្វី។ ឥឡូវនេះជាពេល ដែលត្រូវធ្វើតាមជម្រើសដែលអ្នកបានជ្រើសរើសហើយ។ ចូរជឿថាព្រះជាម្ចាស់នឹងជួយអ្នក ហើយទ្រង់នឹងគង់ជាមួយអ្នក នៅពេលដែលអ្នកបោះជំហានទៅមុខក្នុងការដោះស្រាយបញ្ហារបស់អ្នក។

ជំហានទី៦ : វាយតម្លៃទៅលើលទ្ធផល ដែលបានមកពីដំណោះស្រាយរបស់អ្នក និង ធ្វើការកែតម្រូវផ្សេងៗដែលមាន

ខ្ញុំបានបូកបញ្ចូលជំហាននេះ ព្រោះយើងត្រូវធ្វើការវាយតម្លៃលទ្ធផលរបស់ដំណោះស្រាយដែលយើងបានជ្រើសរើស។ មិនយូរប៉ុន្មាន ក្រោយពេលយើងបានធ្វើការដោះស្រាយបញ្ហាមួយហើយយើងឃើញថា ជម្រើសនោះមិនមែនជាជម្រើសល្អបំផុតនោះទេ ហើយវាចាំបាច់ត្រូវមានការកែតម្រូវបន្ថែមទៀត។ មិនត្រូវអស់សង្ឃឹមឡើយ ប្រសិនបើអ្នកបានធ្វើទៅតាមការវិនិច្ឆ័យដ៏ល្អបំផុតរបស់អ្នក ក្រោយពីបានថ្វាយបញ្ហារបស់អ្នកទៅកាន់ព្រះជាម្ចាស់ហើយ និង បានទូលសូមការដឹកនាំរបស់ទ្រង់ ហើយក្រោយមកអ្នកឃើញថា ដំណោះស្រាយរបស់អ្នកត្រូវបរាជ័យក្នុងការទទួលបានលទ្ធផលដែលជាទីគាប់ចិត្តអ្នក។ ការដោះស្រាយបញ្ហា អាចរៀនបានតាមរយៈបទពិសោធន៍។ ការដោះស្រាយបញ្ហាមិនមែនជាទេពកោសល្យដែលអ្នកទទួលស្នងពីកំណើតនោះឡើយ។ នេះគឺជាពេលវេលាមួយដែលត្រូវមើលទៅក្នុងខ្លួនអ្នកដើម្បីមើលឃើញថាអ្នកបានថ្វាយខ្លួនរបស់អ្នកទាំងស្រុងទៅកាន់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយត្រៀមខ្លួនជាស្រេចដើម្បីដើរទៅកន្លែងណាដែលទ្រង់នាំផ្លូវទៅ។

លំហាត់អនុវត្តន៍

១៤ ដើម្បីសរុបតារាងរបស់អ្នក ចូរសរសេរបន្ថែម សំណួរទី១០ ដោយផ្អែកលើជំហានទី ៦។

ចូរចងចាំផងដែរថា មិនមែនគ្រប់ស្ថានភាពដែលមិនអំណោយផលទាំងអស់សុទ្ធតែជាបញ្ហាដែលត្រូវការ ដំណោះស្រាយប្រភេទនោះឡើយ។ ប្រសិនបើ បញ្ហានោះជាអ្វីដែលមិនអាចផ្លាស់ប្តូរបាន វាត្រូវការការកែតម្រូវតាមបែបផ្សេងទៀត។ សម្រាប់ដំណោះស្រាយប្រភេទនេះ ចូរទៅមើលនៅក្នុងវិធីសាស្ត្រ ខ។

វិធីសាស្ត្រ ខ

ជំហានទី១. ស្គាល់បញ្ហា

ប្រើប្រាស់ដំណើរការដូចនៅក្នុងវិធីសាស្ត្រ ក ដែរ។

ជំហានទី២. ថ្វាយបញ្ហានោះទៅកាន់ព្រះជាម្ចាស់

ប្រើប្រាស់ដំណើរការដូចនៅក្នុងវិធីសាស្ត្រ ក ដែរ។

ជំហានទី៣. រំពឹងថាព្រះជាម្ចាស់ធ្វើការដើម្បីប្រយោជន៍របស់អ្នក ។

នៅពេលដែលលោកសាវ័កប៉ូល បានឃើញថាខ្លួនលោកកំពុងតែជាប់ក្នុងគុក លោកបានដឹងថា លោកមិនអាចផ្លាស់ប្តូរស្ថានភាពនោះបានទេ។ ព្រះជាម្ចាស់មិនបានដោះគាត់ឲ្យចេញពីគុកនៅក្នុងពេលនោះ ដូចនៅពេលដែលទ្រង់បានធ្វើឲ្យព័ន្ធកិច្ចរបស់លោកប៉ូលមានភាពងាយស្រួលកន្លងមកនោះទេ (គម្ពីរកិច្ចការជំពូក១៦) ។ ប៉ុន្តែលោកប៉ូលបានរំពឹងទុកថា ទោះជាយ៉ាងណា ព្រះជាម្ចាស់នឹងធ្វើការសម្រាប់ប្រយោជន៍របស់លោក។ ជាលទ្ធផល ព្រះអម្ចាស់បានប្រើប្រាស់លោកតាមរបៀបដ៏អស្ចារ្យមួយ ក្នុងការចែកចាយដំណឹងល្អទោះបីជាលោកនៅជាប់ក្នុងគុកក៏ដោយ។

ដំណោះស្រាយដ៏ពិតប្រាកដ ចំពោះបញ្ហាប្រភេទនេះ គឺត្រូវទទួលដោយអំណរ នូវអ្វីដែលមិនអាចផ្លាស់ប្តូរបាន និង អនុញ្ញាតឲ្យស្ថានភាពនោះបានក្លាយទៅជាបទពិសោធន៍ដើម្បីឲ្យអ្នកបានលូតលាស់ និង កែច្នៃអ្នកឲ្យមានលក្ខណៈដូចជាព្រះគ្រិស្ត និង ធ្វើឲ្យអ្នកក្លាយជាមនុស្សដែលចេះខ្វល់ខ្វាយ និង មានចិត្តអាណិតអាសូរ។ ចូររំឭកខ្លួនឯងឲ្យបានញឹកញាប់ថា "អ្វីៗទាំងអស់ផ្សំគ្នាឡើង ដើម្បីអោយអស់អ្នកស្រឡាញ់ព្រះជាម្ចាស់ បានទទួលផលល្អ" (គម្ពីររ៉ូម ៨:២៨)។ មិនមែនជារឿងល្អទេ ដែលអ្នកខ្វល់ខ្វាយថា "ស្ថានការណ៍គួរតែទៅជាបែបណា ប្រសិនបើ….." ។ គំនិតបែបនោះ ជាការខាតបង់ពេលវេលា និងកម្លាំងឥតប្រយោជន៍។ អ្នកអាចរំពឹងឲ្យព្រះជាម្ចាស់ធ្វើការដើម្បីផលល្អរបស់អ្នក មិនថាស្ថានភាពរបស់អ្នកជាអ្វីក៏ដោយ។

លំហាត់អនុវត្តន៍

---

១៥ តើបញ្ហាណាខ្លះ ខាងក្រោមនេះ ដែលអ្នកអាចយកវិធីសាស្ត្រ ខ មកអនុវត្តជាមួយបាន?

ក) អ្នកបានបំពានទៅលើមិត្តភក្តិរបស់អ្នកយ៉ាងខ្លាំង ដោយអ្នកបាននិយាយអាក្រក់អំពីគាត់។

ខ) អ្នកត្រូវតែមើលថែ ឪពុកម្តាយមានជំងឺ និង ចាស់ជរា ដែលគាត់គ្មានអ្វីជាទីពឹងបាន។

គ) ប្តីរបស់អ្នកបានស្លាប់ ហើយឥឡូវនេះអ្នកនៅតែម្នាក់ឯង។

ឃ) កន្លែងដែលអ្នកស្នាក់នៅ មានសភាពចាស់ទ្រុឌទ្រោម ប៉ុន្តែវាជាកន្លែងតែមួយគត់ដែលអ្នកអាច មានលទ្ធភាពបង់ថ្លៃបានក្នុងពេលបច្ចុប្បន្ននេះ។

ង) កូនប្រុសវ័យជំទង់របស់អ្នកបាន រត់ចេញពីផ្ទះ ហើយអ្នកមិនដឹងថាគាត់នៅទីណានោះទេ។

ច) អ្នកចង់បន្តការសិក្សារបស់អ្នក ប៉ុន្តែឪពុកម្តាយរបស់អ្នកមិនអាចមានលទ្ធភាពជួយអ្នកបង់ថ្លៃបានទេ។

១៦ ចូរអានគម្ពីរដានីយ៉ែល ១: ១-២០ ហើយធ្វើតាមជំហានក្នុងការដោះស្រាយបញ្ហា ដោយសរសេរបទគម្ពីរ និង ទង្វើនៅពីក្រោយសំណួរនីមួយៗ នៅក្នុងតារាងរបស់អ្នក ដែលបង្ហាញពីរបៀប ដែលលោកដានីយ៉ែលធ្វើការដោះស្រាយតាមផ្នែកនីមួយៗ ដោយមានជំនួយពីព្រះជាម្ចាស់ ។ ប្រសិនបើអ្នកមិនអាចរកឃើញចម្លើយនោះទេ សូមទុកចន្លោះនោះនៅទទេ។ ចូរផ្សារភ្ជាប់សំណួរ នីមួយៗទៅជាមួយនឹងស្ថានភាពរបស់លោកដានីយ៉ែល ឧទាហរណ៍៖ សំណួរទី១ គួរតែសួរយ៉ាងដូច្នេះ " តើបញ្ហារបស់លោកដានីយ៉ែលជាអ្វី?" រួចសរសេរចម្លើយនៅក្នុងសៀវភៅសរសេររបស់អ្នក។

១៧ ឥឡូវនេះ ចូរយកវិធីសាស្ត្រ ក និង វិធីសាស្ត្រ ខ ទៅអនុវត្តនៅក្នុងព្រឹត្តិការណ៍ដែលបានកត់ត្រានៅក្នុងគម្ពីរ ដានីយ៉ែល ៦:១- ២៨។ តើវិធីសាស្ត្រមួយណា ដែលអាចផ្តល់ដំណោះស្រាយនៅក្នុងករណីមួយនេះ?

....

ឃ. អរសប្បាយ និង អរព្រះគុណ

វត្ថុបំណងទី៥. *ប្រាប់ពីគោលការណ៍មួយដែលបកស្រាយពីអ្វីដែលបានជួយលោកសាវ័កប៉ូលឲ្យបានសប្បាយចិត្តនៅក្នុងគ្រប់កាលៈទេសៈទាំងអស់។*

គោលការណ៍ចុងក្រោយនៅក្នុងការឆ្លើយតបរបស់គ្រិស្តបរិស័ទចំពោះការដោះស្រាយបញ្ហា គឺការថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ៖ "ចូរមានអំណរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាលៈទេសៈទាំងអស់ ដ្បិតព្រះអង្គសព្វព្រះហឫទ័យអោយបងប្អូន ដែលរួមជាមួយព្រះគ្រិស្តយេស៊ូធ្វើដូច្នេះឯង" (គម្ពីរ១ថែស្សាឡូនិក ៥:១៦-១៨)។ ចូរបន្តការសរសើរតម្កើងព្រះជាម្ចាស់។ នៅពេលណាដែលគំនិតរបស់អ្នក មិនគិតអំពីរឿងរ៉ាវចាំបាច់នោះទេ ចូរបង្កើតទម្លាប់ អនុញ្ញាតឲ្យ មានការសរសើរតម្កើងព្រះជាម្ចាស់យ៉ាងស្ងៀមស្ងាត់ហូរនៅក្នុងគំនិតរបស់អ្នក។ ការអនុវត្តយ៉ាងសាមញ្ញមួយនេះនឹងផ្លាស់ប្រែគំនិតរបស់អ្នក។ ចូរសរសើរតម្កើងទ្រង់ សម្រាប់ក្តីស្មោះត្រង់របស់ទ្រង់ សម្រាប់ការដែលទ្រង់ឈរជាមួយអ្នកក្នុងគ្រប់បញ្ហាទាំងអស់។

ចូរចែកចាយដំណឹងល្អរបស់អ្នកជាមួយអ្នកដទៃ ដូចលោកប៉ូលបានធ្វើដូច្នោះដែរ! លោកប៉ូលបានសរសេរអំពីភាពស្មោះត្រង់របស់គ្រិស្តបរិស័ទ នៅពេលដែលលោកសរសេរសំបុត្រផ្ញើទៅកាន់មិត្តភក្តិរបស់គាត់ដែលជាគ្រិស្តបរិស័ទនៅក្រុងភីលីព (គម្ពីរភីលីព ១:១២)។ លោកមិនចង់ឲ្យពួកគេមានអារម្មណ៍អាណិតលោកនោះទេ! លោកបានថ្លែងទាំងមានអំណរថា៖ " គឺគ្រប់ពេល ខ្ញុំទូលអង្វរព្រះជាម្ចាស់សំរាប់បងប្អូនទាំងអស់គ្នា ខ្ញុំទូលអង្វរដោយចិត្តរីករាយជាដរាប ព្រោះបងប្អូនរួមចំណែកក្នុងការផ្សាយដំណឹងល្អតាំងពីថ្ងៃដំបូង រហូតមកទល់សព្វថ្ងៃ" (គម្ពីរភីលីព ១:៤-៥) ។ លោកប៉ូលក៏បានចែកចាយពីពួកគេ អំពីរឿងខ្លះៗ ដែលលោកបានរៀននៅពេលដែលលោកបានអនុញ្ញាតឲ្យព្រះជាម្ចាស់ធ្វើការដោះស្រាយបញ្ហានៅក្នុងជីវិតរបស់គាត់៖

ខ្ញុំនិយាយដូច្នេះ មិនមែនមកពីខ្ញុំខ្វះខាតទេ ដ្បិតខ្ញុំបានរៀនអោយចេះស្កប់ចិត្ត ក្នុងគ្រប់កាលៈទេសៈ។ ទោះបីទ័លក្រក្ដី មានបរិបូណ៌ក្ដី ខ្ញុំក៏ចេះរស់ដែរ។ ខ្ញុំបានអប់រំចិត្តក្នុងគ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែង គឺថាទោះបីបរិភោគឆ្អែតក្ដី អត់ឃ្លានក្ដី មានបរិបូណ៌ក្ដី ឬខ្វះខាតក្ដី ខ្ញុំស្កប់ចិត្តជានិច្ច។ ខ្ញុំអាចទ្រាំបានទាំងអស់ ដោយរួមជាមួយព្រះអង្គដែលប្រទានកម្លាំងអោយខ្ញុំ។ (គម្ពីរភីលីព ៤:១១-១៣)

លំហាត់អនុវត្តន៍

១៨ តើគោលការណ៍អ្វីខ្លះ នៅក្នុងមេរៀននេះ បានបកស្រាយអ្វីដែលបានជួយលោកប៉ូលបាន សប្បាយចិត្ត និង មានអំណរ នៅក្នុងស្ថានភាពគ្រប់ប្រភេទទាំងអស់?

....

១៩ បទគម្ពីរនេះ បង្ហាញថា គុណតម្លៃដែលសំខាន់អស្ចារ្យជាងគេបង្អស់សម្រាប់លោកប៉ូល គឺ

ក) គុណតម្លៃដែលនៅលើផែនដីក្នុងពេលបច្ចុប្បន្ន។

ខ) គុណតម្លៃដ៏អស់កល្បជានិច្ច។

នៅពេលដែលអ្នកដឹងថា ព្រះគ្រិស្តជាម្ចាស់លើគ្រប់ស្ថានភាពគ្រប់បែបយ៉ាង ដែលកើតមាននៅក្នុងជីវិតរបស់យើង ជាម្ចាស់ដែលខ្វល់ព្រះទ័យចំពោះយើង ហើយជាម្ចាស់ដែលតែងតែធ្វើការសម្រាប់ប្រយោជន៍ដ៏អស់កល្បជានិច្ចរបស់យើង យើងមិនអាចធ្វើអ្វីបានទេក្រៅពីសរសើរតម្កើងទ្រង់។ ទ្រង់ស័ក្តិសមទទួលការសរសើររបស់យើង!

ឥឡូវនេះ យើងត្រៀមខ្លួនរួចជាស្រេច ដើម្បីពិចារណាអំពីបញ្ហាពិសេសៗដែលកើតឡើងច្រើនទៅលើមនុស្ស ហើយជាបញ្ហាដែលអ្នកអាចនឹងត្រូវប្រឈមមុខ។ នៅក្នុងជំពូកបន្ទាប់ យើងនឹងពិភាក្សាគ្នាអំពីបញ្ហានៅក្នុងទំនាក់ទំនង។ យើងអធិស្ឋាន សូមឲ្យការសិក្សានេះ ក្លាយជាជំនួយដ៏ល្អសម្រាប់អ្នក។

ការប្រឡងផ្ទាល់ខ្លួន

នៅក្នុងការប្រឡងផ្ទាល់ខ្លួននេះ យើងនឹងរៀបរាប់អំពីស្ថានភាពបញ្ហាខ្លះៗ និង លទ្ធផលរបស់បញ្ហាទាំងនោះ បន្ទាប់មកយើងនឹងផ្តល់ឱកាសឲ្យអ្នកយកគោលការណ៍ នៅក្នុងមេរៀននេះទៅអនុវត្ត ដើម្បីឲ្យបានមើលឃើញថាវាអាចដោះស្រាយបាន តាមរបៀបមួយដែលល្អប្រសើរជាង។ ក្រោយពេល អ្នកបានធ្វើការប្រឡងផ្ទាល់ខ្លួននេះ រួចរាល់ហើយ ចូរប្រៀបធៀបចម្លើយរបស់អ្នកជាមួយនឹងចម្លើយរបស់យើង(ក្នុងមេរៀននេះ)។

១ រ៉េម៉ន និង អាឡៃន ជាកូនរបស់គ្រួគង្វាលម្នាក់នៃក្រុមជំនុំតូចមួយ ហើយគាត់មានចំណូលបន្តិចបន្តួចតែប៉ុណ្ណោះ។ រ៉េម៉ន ប្រាថ្នាចង់ក្លាយជាវេជ្ជបណ្ឌិតម្នាក់។ នៅពេលដែលគាត់ ឈានដល់អាយុដែលអាចរៀនមហាវិទ្យាល័យបាន ឪពុកម្តាយរបស់គាត់បានសម្រេចចិត្តប្រើប្រាស់លុយដែលពួកគេបានសន្សំ ដើម្បីបញ្ជូនរ៉េម៉នទៅរៀននៅសាលាវេជ្ជសាស្ត្រ។ នោះមានន័យថា ពួកគេគ្មាននៅសល់ប្រាក់សម្រាប់ជួយឲ្យអាឡៃនចូលរៀនមហាវិទ្យាល័យបានទេ។ ឪពុកម្តាយរបស់នាងបានរំពឹងថា នាងនឹងអាចរៀបការ ហើយមិនត្រូវការការអប់រំនៅក្នុងមហាវិទ្យាល័យនោះទេ។ ប៉ុន្តែ អាឡៃនក៏មានក្តីស្រមៃចង់រៀនមហាវិទ្យាល័យដែរ ហើយការសម្រេចចិត្តរបស់ឪពុកម្តាយរបស់នាង ពិតជាធ្វើឲ្យនាងខកបំណងខ្លាំងណាស់។ ដោយឪពុកម្តាយរបស់នាង មិនអាចជួយនាងបាន អាឡៃនក៏កើតមានអារម្មណ៍ស្រណោះខ្លួនឯង។ នាងក៏ចាប់ផ្តើម ទាញខ្លួនឯងចូលទៅក្នុងពិភពមួយដែលមានតែនាងម្នាក់ឯង ចាប់ផ្តើមចំណាយពេលរបស់នាង ទួញសោកចំពោះការសម្រេចចិត្តរបស់ឪពុកម្តាយនាង។ ភាពក្រៀមក្រំយ៉ាងខ្លាំងនៅក្នុងគំនិតរបស់នាង ស្ទើរតែបំផ្លាញសុខភាពរបស់នាងទៅហើយ។ ជាច្រើនសប្តាហ៍ នាងបានសំរាកនៅក្នុងមន្ទីរពេទ្យដែល បងប្រុសរបស់នាងកំពុងតែធ្វើការហ្វឹកហាត់ការងារនៅទីនោះផងដែរ។ រ៉េម៉នជាគ្រិស្តបរិស័ទ ដ៏ស្មោះត្រង់ម្នាក់។ អាឡៃនក៏ជាគ្រិស្តបរិស័ទម្នាក់ផងដែរ ប៉ុន្តែនាងបានចុះចាញ់បញ្ហារបស់នាងទៅហើយ។

ក) តើបញ្ហារបស់អាឡៃន ជាអ្វី?

....

ខ) តើអ្វីជា ប្រភពនៃបញ្ហារបស់នាង?

....

គ) តើអាឡៃន ឆ្លើយតបទៅចំពោះបញ្ហារបស់នាងដោយរបៀបណា?

....

ឃ) ប្រសិនបើ អាឡៃនបានធ្វើតាមគោលការណ៍សម្រាប់ការដោះស្រាយបញ្ហា ដែលមាននៅក្នុងមេរៀននេះ តើនឹងអាចមានដំណោះស្រាយអ្វីសម្រាប់នាង? អ្នកប្រហែលជាអាចគិតឃើញច្រើនជាងមួយ។

....

....

....

ង) តើបទគម្ពីរដែលយើងទើបនឹងបានរំឭក មានរៀបរាប់អ្វីខ្លះ អំពីមធ្យោបាយដែលអាឡែនគួរតែជ្រើសយកសម្រាប់ការស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់នាង?

....

២ លោក ច័រដាន គឺជាអ្នកជំនួយគ្រិស្តបរិស័ទម្នាក់ដែលជាម្ចាស់ផ្សារលក់សាច់មួយ។ នៅថ្ងៃមួយគាត់បានទិញ សត្វចៀមខ្លះពីមិត្តរបស់គាត់ឈ្មោះ ដាវីឌ ដែលជាគ្រិស្តបរិស័ទម្នាក់ដែរ។ លោកច័រដានលោកបានពិឃាដ សត្វចៀមទាំងនោះ ប៉ុន្តែអ្នកត្រួតពិនិត្យសុខភាព មិនអនុញ្ញាតឲ្យដាក់លក់សាច់នោះឡើយ ដោយគេនិយាយថា សាច់នោះមានជំងឺ ហើយត្រូវតែបំផ្លាញចោល។ លោកច័រដាន ពិតជាខឹងចិត្តខ្លាំងណាស់ គាត់បានទៅរកលោកដាវីឌ ហើយទាមទារប្រាក់របស់លោកមកវិញ។ លោកដាវីឌ មិនទទួលស្គាល់ថាចៀមទាំងនោះមានជំងឺនៅពេលលក់នោះទេ ហើយក៏មិនព្រមសងប្រាក់វិញដែរ។ ដោយខឹងខ្លាំងណាស់ លោកច័រដាន បានដាក់ពាក្យបណ្ដឹងលោកដាវីឌ។ នៅពេលដែលគ្រូគង្វាលរបស់ពួកគេបានឮអំពីបញ្ហានេះ គាត់បានព្យាយាមអញ្ជើញលោកដាវីឌ និង លោកច័រដានមក ហើយពិភាក្សាគ្នាអំពីបញ្ហានោះជាមួយគាត់ និងព្យាយាមដោះស្រាយបញ្ហាជាមួយមធ្យោបាយរបស់គ្រិស្តបរិស័ទ។ គ្រូគង្វាលបានរំឭកអ្នកទាំងពីរបទគម្ពីរហាមមិនឲ្យគ្រិស្តបរិស័ទយកជម្លោះរបស់ពួកគេទៅឲ្យពួកមនុស្សមិនបរិសុទ្ធ (គម្ពីរ ១កូរិនថូស ៦:១-៨) ។ ប៉ុន្តែ លោកច័រដានមិនព្រមស្ដាប់ទេ ហើយបានឈានទៅរកការប្ដឹងតែម្ដង។ លោកច័រដាន និង លោកដាវីឌ លែងជាមិត្តនឹងគ្នាទៀតហើយ ព្រមទាំងធ្វើឲ្យក្រុមជំនុំបានអារម្មណ៍ថាបរាជ័យផងដែរ។

ក) តើគោលការណ៍ នៃការដោះស្រាយបញ្ហា អ្វីខ្លះដែលលោកច័រដាន គួរតែអនុវត្តតាមដើម្បីដោះស្រាយបញ្ហារបស់គាត់តាមបែបគ្រិស្តបរិស័ទ?

....

....

ខ) តើលទ្ធផលចុងក្រោយដែលបានមកពីអាកប្បកិរិយារបស់គាត់ ជាអ្វី?

....

....

គ) តើបញ្ហានោះគួរតែទៅជាយ៉ាងណាវិញ?

....

....

ឃ) ចូរអនុវត្តជំហាននៃការដោះស្រាយបញ្ហា ដើម្បីបង្ហាញឲ្យឃើញពីរបៀបដែលបញ្ហានេះគួរតែត្រូវបានដោះស្រាយយ៉ាងជោគជ័យ និងដើម្បីសរសើរតម្កើងព្រះជាម្ចាស់។ ចូរសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

៣ លោកចេម និង អ្នកស្រី អែសធើរ បានរៀបការអស់រយៈពេលដប់ឆ្នាំមកហើយ ប៉ុន្តែពួកគេមិនមានកូនសោះ។ ពួកគាត់ទាំងពីរនាក់មានបំណងចង់បានកូនខ្លាំងណាស់ ហើយបានអធិស្ឋាន ជាច្រើនដងមកដែរ ដើម្បីឲ្យព្រះជាម្ចាស់បំពេញតម្រូវការរបស់ពួកគាត់។ ពួកគេបានស្វែងរក ជំនួយពីថ្នាំ ពេទ្យ ប៉ុន្តែគ្មានគ្រូពេទ្យណាអាចជួយគាត់បានឡើយ។ នៅក្នុងពេលជាមួយគ្នានោះ ដែរ ពួកគាត់បានថ្វាយការបម្រើរបស់ពួកគាត់ទៅគ្រូគង្វាល ដើម្បីធ្វើការជាមួយក្មេងៗ នៅក្នុង ក្រុមជំនុំ ហើយព្រះជាម្ចាស់បានប្រទានពរដល់ព័ន្ធកិច្ចរបស់ពួកគាត់ក្នុងការបង្រៀនក្មេងៗជា ច្រើន និង បាននាំពួកគេមកឯព្រះអម្ចាស់។ ជីវិតរបស់ពួកគាត់ មានពោរពេញទៅដោយការ សរសើរតម្កើងសម្រាប់ព្រះជាម្ចាស់។

ក) តើវិធីសាស្ត្រនៃការដោះស្រាយបញ្ហាមួយណា ដែលបានយកមកអនុវត្តនៅត្រង់នេះ?

....

ខ) ចូរប្រើប្រាស់តារាងរបស់អ្នក ដើម្បីបង្ហាញពីរបៀបដែលលោកចែម និង អ្នកស្រីអែសធើរ ដោះស្រាយបញ្ហារបស់ពួកគាត់។ ចូរសរសេរ ចម្លើយរបស់អ្នកនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

៤ ចូរប្រើប្រាស់តារាងរបស់អ្នក សម្រាប់បញ្ហានៅក្នុងជីវិតរបស់អ្នកផ្ទាល់ ឬ នៅក្នុងជីវិតរបស់ នរណាម្នាក់ដែលអ្នកស្គាល់។ ចូរអនុវត្តជំហាននីមួយៗដែលបានផ្តល់ជូន ហើយជឿថា ព្រះជាម្ចាស់នឹងជួយអ្នកដើម្បីស្វែងរកដំណោះស្រាយយ៉ាងត្រឹមត្រូវ។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១០ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយទាំងនេះ៖

១.	តើបញ្ហារបស់ខ្ញុំជាអ្វី?
២.	តើប្រភពនៃបញ្ហានោះជាអ្វី?
៣.	តើបញ្ហានោះមានប្រភពស៊ីជម្រៅជាងនេះ ដែលខ្ញុំគួរតែពិចារណាដែរឬទេ?
៤.	តើបញ្ហានោះមាន ដំណោះស្រាយដ៏ជាក់លាក់មួយបានដែរឬទេ?

១ ចម្លើយរបស់អ្នក។ អ្នកគួរតែឆ្លើយដូចខាងក្រោមនេះ៖

ក) បញ្ហាពិតប្រាកដ គឺ*ការមិនស្តាប់បង្គាប់ព្រះជាម្ចាស់* ដែលរួមមាន ខកខានការអានព្រះបន្ទូលរបស់ទ្រង់ ខកខាកការអធិស្ឋាន និង មិនបានរក្សាថ្ងៃរបស់ទ្រង់ជាវិសុទ្ធ (ការចូលរួមក្នុងព្រះវិហារ)។

ខ) ប្រភពនៃបញ្ហាគឺជា និស្ស័យបាប។

គ) ដំណោះស្រាយតាមសុភនិច្ឆ័យគួរតែជា *ការលន់តួបាប* និង *ការស្តាប់បង្គាប់* ព្រះជាម្ចាស់។ ដំណោះស្រាយនេះនឹងរៀបចំវិញ្ញាណគូស្វាមីភរិយានោះ ឲ្យប្រឈមមុខជាមួយបញ្ហាផ្សេងៗទៀតដែលកើតមានឡើង។

១១

៥.	តើខ្ញុំបានទូលថ្វាយព្រះជាម្ចាស់អំពីបញ្ហានេះហើយឬនៅ?

២ ប្រសិនបើ អ្នកបានឆ្លើយថា *ទេ* ទៅចំពោះសំណួរណាមួយ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យធ្វើតាមជំហានដែលចាំបាច់ដើម្បីធ្វើការកែតម្រូវស្ថានភាពនោះ។

១២

៦.	តើមានគោលការណ៍តាមបទគម្ពីរ សម្រាប់យកមកអនុវត្តនៅក្នុងបញ្ហានេះបានដែរឬទេ? តើគោលការណ៍ទាំងនោះមានអ្វីខ្លះ?
៧.	តើខ្ញុំត្រូវការជំនួយពីមិត្តភក្តិ ឬ អ្នកប្រឹក្សាយោបល់ដែលជាគ្រិស្តបរិស័ទ ដើម្បីស្វែងរកដំណោះស្រាយនេះដែរឬទេ?
៨.	តើដំណោះស្រាយអ្វីខ្លះ ដែលស្របទៅតាមសេចក្តីបង្រៀននៅក្នុងបទគម្ពីរ?

៣ ក) ២) ការចោទប្រកាន់

ខ) ៤) ការសងសឹក; ១) កំហឹង

គ) ៣) ទាស់ចិត្ត

ឃ) ១) កំហឹង

១៣

៩. តាមការវិនិច្ឆ័យដែលល្អបំផុតរបស់ខ្ញុំ ក្រោយពេលធ្វើតាមជំហានដើម្បីស្វែងរកដំណោះស្រាយនេះហើយ តើដំណោះស្រាយមួយណា នឹងជាដំណោះស្រាយល្អបំផុតសម្រាប់ខ្ញុំ ក្នុងនាមជាគ្រិស្តបរិស័ទ?

៤ ខ) ភាពអាត្មានិយម

គ) ស្រណោះខ្លួន

ច) ភាពល្ងីងជូរចត់

ឆ) កំហឹង

១៤

១០. តើខ្ញុំពេញចិត្តជាមួយនឹងដំណោះស្រាយនោះហើយឬនៅ ឬ តើខ្ញុំត្រូវការធ្វើការកែតម្រូវអ្វីផ្សេងទៀតដែរឬទេ?

ចំណាំ៖ ប្រសិនបើ ត្រូវការការកែតម្រូវបន្ថែម ចូរអ្នកត្រឡប់ទៅជំហានទី១ ម្តងទៀត ហើយធ្វើការដោះស្រាយបញ្ហានោះម្តងទៀត។

៥ ប្រសិនបើ ចម្លើយរបស់អ្នកគឺ បាទ/ចាស ចំពោះសំណួរណាមួយ អ្នកត្រូវគិតគូរ និង អធិស្ឋានបន្ថែមទៀតដើម្បីស្វែងរករបៀបវិជ្ជមានក្នុងការដោះស្រាយបញ្ហារបស់អ្នក។ ចូរទូលសូមព្រះអម្ចាស់ឲ្យជួយអ្នកស្គាល់ ការឆ្លើយតបដែលខុសឆ្គងទៅចំពោះបញ្ហានៅក្នុងថ្ងៃអនាគត និង អាចជៀសពីវាបាន។

១៥ អ្នកអាចយកវិធីសាស្ត្រ ខ ទៅប្រើប្រាស់នៅក្នុងបញ្ហា ខ), គ), ឃ) និង ង)បាន។ អ្នកអាចយក វិធិសាស្ត្រ ក ទៅប្រើប្រាស់នៅក្នុងបញ្ហា ក) និង ច)បាន។

៦ ខ) ព្រះអម្ចាស់

១៦

សំណួរ	ចម្លើយ
១. តើបញ្ហារបស់លោកដានីយ៉ែលមានអ្វីខ្លះ?	គាត់ត្រូវបានគេបង្ខំឲ្យបរិភោគអាហារដែលអាចនឹងធ្វើឲ្យគាត់មិនបរិសុទ្ធ ដោយយោងទៅតាមការណែនាំរបស់ព្រះជាម្ចាស់សម្រាប់ជនជាតិហេប្រឺ (គម្ពីរដានីយ៉ែល ១:៥,៨)
២. តើប្រភពនៃបញ្ហាជាអ្វី?	ស្តេច
៣. តើមានប្រភពដែលជ្រៅជាងនេះដែរឬទេ?	អត់ទេ
៤. តើអាចមានដំណោះស្រាយដ៏ប្រាកដមួយ ដែរឬទេ?	អាចមាន
៥. តើលោកដានីយ៉ែលបានទូលថ្វាយរឿងនេះទៅកាន់ព្រះជាម្ចាស់ដែរឬទេ?	បានទូល។ ការនេះត្រូវបានបង្ហាញឲ្យឃើញនៅក្នុងខទី៨ ទី៩ និង ទី១៧ ។ ព្រះជាម្ចាស់បាន ប្រោសប្រទានអោយលោកអាសផ្នាសជានាយកក្រុមមហាតលិក មានចិត្តអាណិតអាសូរដល់យុវជនដានីយ៉ែល និង មិត្តភក្តិរបស់គាត់។
៦. តើមានគោលការណ៍តាមបទគម្ពីរដែលអាចយកមកប្រើប្រាស់នៅក្នុងបញ្ហានេះបានដែរឬទេ?	ពិតជាមាន។ លោកដានីយ៉ែលបានដឹងថា ព្រះជាម្ចាស់បានប្រកាសថាអាហារខ្លះ គឺមិនបរិសុទ្ធនោះទេ។ (ឧទាហរណ៍ សូមមើលនៅក្នុងគម្ពីរលេវីវិន័យ ១០:៩ និង ជំពូកទី ១១)
៧. តើលោកដានីយ៉ែលត្រូវការជំនួយក្នុងការស្វែងរកដំណោះស្រាយដែរឬទេ?	មិនចាំបាច់ទេ។ លោកបានដឹងច្បាស់ថា អាហារនោះនឹងធ្វើប្រមាថលោក (ធ្វើឲ្យលោកមិនបរិសុទ្ធនៅចំពោះព្រះជាម្ចាស់) (ខទី៨)
៨. តើដំណោះស្រាយអ្វីដែលស្របទៅតាមសេចក្តីបង្រៀននៅក្នុងបទគម្ពីរ?	មិនត្រូវបរិភោគអាហារនោះឡើយ។
៩. តើដំណោះស្រាយអ្វីដែលលោកដានីយ៉ែលបានជ្រើសរើសថាសម្រាប់លោកក្នុងនាមជាមនុស្សដែលព្រះជាម្ចាស់បានជ្រើសរើសនោះ?	លោកជ្រើសយកការមិនបរិភោគអាហារនោះទេ។ លោកបានជ្រើសរើស ការសាកល្បងរយៈពេល១០ថ្ងៃដោយបរិភោគតែបន្លែ និងទឹកតែប៉ុណ្ណោះ (ខទី ១១ ដល់ ទី១៣) ។ លោកបានសុំឲ្យអាសផ្នាសជានាយកមហាតលិក និង អ្នកយាមជួយលោក ហើយលោកមិនបរិភោគអាហាររបស់ស្តេចនោះឡើយ។ ការសាកល្បងរយៈពេលដប់ថ្ងៃនោះ ទទួលបានជោគជ័យ ហើយប្រជាជនហេប្រឺក៏បន្តបរិភោគតែបន្លែ និង ទឹក ប៉ុណ្ណោះ (ខទី ៨, ១១ - ១៦)

១០. តើចាំបាច់ត្រូវមានការកែតម្រូវបន្ថែមទៀតដែរឬទេ?	មិនចាំបាច់ទេ។ ព្រះជាម្ចាស់សរសើរចំពោះការសម្រេចចិត្តរបស់លោកដានីយ៉ែល ដោយប្រទានពរដល់លោក (ខ១៧ , ២០)

៧ ខ) ការយល់ដឹងរបស់អ្នកផ្ទាល់ (អ្វីដែលអ្នកគិតថាអ្នកដឹង)

១៧ វិធីសាស្រ្ត ខ គឺជាវិធីសាស្រ្តមួយដែលលោកដានីយ៉ែលបានប្រើប្រាស់នៅក្នុងរឿងរ៉ាវមួយនេះ លោកបានដោះស្រាយបញ្ហារបស់លោក ថ្វាយវាទៅកាន់ព្រះជាម្ចាស់ និង រំពឹងថាទ្រង់នឹងធ្វើការសម្រាប់ផលល្អរបស់លោក។ លោកមិនអាចនឹងស្តាប់បង្គាប់ស្តេច ដោយមិនល្មើសចំពោះព្រះជាម្ចាស់នោះឡើយ។ លោកបានជ្រើសរើសគុណតម្លៃដ៏អស់កល្បជានិច្ច ហើយព្រះជាម្ចាស់សរសើរការសម្រេចចិត្តរបស់លោក។

៨ ក) បង្ហាញអ្នកពីផ្លូវត្រឹមត្រូវដែលត្រូវដើរ។

១៨ គោលការណ៍នៃការទុកចិត្តលើព្រះជាម្ចាស់សម្រាប់ផលល្អរបស់លោក នៅក្នុងគ្រប់ស្ថានភាពទាំងអស់។

៩ ព្រោះ ការយល់ដឹងរបស់អ្នក មានដែនកំណត់ ហើយអ្នកមិនអាចដឹងពីដំណោះស្រាយល្អបំផុតនោះទេ ក៏ដោយសារតែ មានបញ្ហាខ្លះអាចដោះស្រាយបានដោយគ្រាន់តែទុកចិត្តលើព្រះជាម្ចាស់ ដែលព្រះអាចធ្វើរឿងដែលមិនអាចទៅរួចបាន។

១៩ ខ) គុណតម្លៃដ៏អស់កល្បជានិច្ច។

ការប្រឡងជំពូកទីមួយ

ពេលនេះ ដោយអ្នកបានបញ្ចប់ជំពូកទី១ ជាស្ថាពរ អ្នកអាចឆ្លើយសំណួរការប្រឡងជំពូកទីមួយបានហើយ។ សូមរំឭកមេរៀនកន្លងមកឡើងវិញ មុនពេលដែលអ្នកចាប់ផ្តើម។ សូមធ្វើតាមការណែនាំដោយយកចិត្តទុកដាក់ ដើម្បីសម្រេចការប្រឡងនេះ ហើយសូមបន្តទៅជំពូកទីពីរទៀត។